## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

### មហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ីឆ្នាំ២០១៦

### ការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជា

ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦

កម្មវិធីប្រលងជ្រើសរើសវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជានៃមហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ីប្រព្រឹត្តិទៅបានយ៉ាងជោគជ័យនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងដោយស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន។ ប្រធានបទដែលត្រូវបកស្រាយក្នុងឆ្នាំនេះគឺ **“រឿងដែលខ្ញុំស្អប់”**។ មានភាពយន្តចំនួន៥៦ រឿងដែលផលិតដោយសិស្សវិទ្យាល័យទូទាំងប្រទេសកម្ពុជា បានដាក់ពាក្យចូលរួមប្រកួត ហើយក្នុងចំណោមនោះមានភាពយន្តចំនួន១៦ បានសម្រិតសម្រាំងដើម្បីចាក់បញ្ចាំងក្នុងការប្រកួតនេះ។



**រូបថតជាមួយគណៈកម្មការ**

មហោស្រពភាពយន្តនេះ បានចាប់ផ្តើមនៅប្រទេសជប៉ុនតាំងពីឆ្នាំ២០០៧មកម្លេះ ហើយចាប់តាំងពីពេលនោះមកគឺមហោស្រពនេះបានចាប់ផ្តើមប្រារព្ធឡើងជារៀងរាល់ឆ្នាំ។ ចំណែកសិស្សនុសិស្សកម្ពុជាវិញត្រូវបានអញ្ជើញអោយចូលរួមក្នុងមហោស្រពនេះតាំងពីឆ្នាំ ២០០៩។ ក្នុងឆ្នាំនេះ សិស្ស៣ក្រុមដែលមានចំនួនសរុប៩រូបនឹងត្រូវបានអញ្ជើញទៅកាន់ប្រទេសជប៉ុន ក្រោមកម្មវិធី JENESYS2016 ជាមួយបណ្តាសិស្សមកពីប្រទេសអាស៊ានទាំង ១០ (មានប្រទេសកម្ពុជា ឥណ្ឌូនេស៊ី សឹង្ហបូរី ថៃឡង់ដ៍ ហ្វីលីពីន ឡាវ ភូមា ព្រុយណេ វៀតណាម ម៉ាឡេស៊ី) ព្រមជាមួយប្រទេសទីម័រខាងកើត កូរ៉េខាងត្បូង ម៉ុងហ្គោលី ប្រទេសចិនតៃវ៉ាន់ និងប្រទេសជប៉ុន។ ពួកគេនឹងចូលរួមវគ្គផ្តាច់ព្រ័ត្រនៃមហោស្រពនេះនៅទីក្រុងគីតាមិ កោះហុកកៃដូ ប្រទេសជប៉ុន នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៦។

**ភាពយន្តខ្លីចំនួន៣រឿងដែលបានជ្រើសរើសចូលរួមក្នុងជុំផ្តាច់ព្រ័ត្រមហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ីឆ្នាំ២០១៦នេះមានរាយដូចខាងក្រោម៖**

| Prize | Name of Students | Film Titles | High Schools |
|---|---|---|---|
| 1st | Veal Chanraksmey<br>Phann Sopheaktra<br>Sreng Mengzeang | The Scar | Beltei Institute |
| 2nd | Chon Chanpisey<br>Khay Kimchhun<br>Te Mouyleng | Remorse | Chbar Ampov High School |
| 3rd | Chek Vyrak<br>Bin Chaknik<br>Piseth Mealtey | Nobody Care | Cambodia Adventist School |